ទ្រឹស្តីនៃការបង្រៀន និងការរៀន



បង្រៀនដោយ៖ យិន វណ្ឌី

មាតិកា

សេចក្តីផ្តើម


៣.១ តើអ្វីជាការរៀន?

៣.២ ប្រភេទផ្សេងគ្នានៃការរៀន

៣.៣ ការអប់រំមានន័យថាការរីកចម្រើន

៣.៤ តើការបង្រៀនមានន័យដូចម្តេច?

៣.៥ ទ្រឹស្តីនៃការរៀន និងការតម្រង់ទិសផ្លូវចិត្ត



បង្រៀនដោយ៖ យិន វណ្ណី

សេចក្តីផ្តើម

- នៅក្នុងថ្នាក់រៀនសម័យទំនើបគ្រូមានកិច្ចការជាច្រើនដែលត្រូវធ្វើ មិនមែនបង្កើតការបង្រៀនតាមអារម្មណ៍ ឬសម្តីគ្រោតគ្រាតទេ។
- ការងារដែលគ្រូបង្រៀនត្រូវធ្វើគឺថែរក្សារបៀបរៀបរយ, សណ្តាប់ធ្នាប់, សីតុណ្ហភាពថ្នាក់រៀន, ចលនាខ្សល់ក្នុងបន្ទប់, ភ្លើងបំភ្លឺក្នុងថ្នាក់រៀន, សុខភាពរាងកាយសិស្ស, លទ្ធផលការងារ, សៀវភៅ, ផែនទី, គំនូសតាង, ខ្មៅដៃ, ក្រដាស និងការផ្តល់សម្ភារៈឧបទេសផ្សេងទៀតដល់សិស្សយកទៅប្រើឱ្យបានត្រឹមត្រូវ។



ប៉ែនៀនដោយ៖ យិន វណ្ណី

សេចក្តីផ្តើម



- ការបង្រៀននិងការរៀន គឺជាការបញ្ចូលគ្នានៃពាក្យ "ការបង្រៀនល្អ" និង "ការរៀនប្រកបដោយប្រសិទ្ធភាព"។
- ប្រសិនបើសិស្សមិនធ្វើសកម្មភាព, មិនបានចូលរួម និងគ្មានឆន្ទៈរៀនទេ ទោះបីជាគ្រូល្អមានសមត្ថភាពបែបណាក៏ដោយក៏នៅតែឥតប្រយោជន៍ដែរ។

បង្រៀនដោយ៖ យិន វណ្ណៈ

១. តើ“ការរៀន”មានន័យដូចម្តេច ?

- ការរៀនមានន័យថា ផ្លាស់ប្តូរនៅក្នុងឥរិយាបថ ឬការប្រព្រឹត្ត ។
- ការរៀនមានន័យថា ជាការធ្វើឱ្យប្រសើឡើងក្នុងការប្រព្រឹត្ត ឬឥរិយាបថដែលមានន័យថាបង្កើតឱ្យមានគំនិតកាន់តែច្បាស់តាមរយៈការធ្វើឡើងវិញ ។
  - ជាការបង្កើតគំនិតច្បាស់លាស់ ។
  - ការរៀនមានន័យថា ជាសកម្មភាពផ្លូវចិត្ត ។



បង្រៀនដោយ៖ យិន វណ្ណៈ

២. ប្រភេទផ្សេងគ្នានៃការរៀន

- ការបង្រៀនជាសិល្បៈនៃការជំរុញ និងដឹកនាំការរៀន ។ ការរៀនជាដំណើរការនៃការបង្កើតគំនិតច្បាស់លាស់ដែលជួយដឹកនាំ និងគ្រប់គ្រងការប្រព្រឹត្ត ឬឥរិយាបថសិស្ស ។ តើគំនិតនេះកើតចេញមកពីណា ? តើវាតំណាងឱ្យអ្វី ?
- គំនិតភាគច្រើនដែលយើងបានរៀនពីនរណាម្នាក់ ហើយគេម្នាក់នោះគឺបានរៀនពីអ្នកផ្សេងទៀត ។ ដើមឡើយនរណាម្នាក់“បង្កើត” ឬប្រើកម្លាំងពលកម្មច្រើន ឬតិចដើម្បីបង្កើតគំនិត ឬការបង្កើតថ្មី ។ របកគំហើញ ឬការបង្កើតគំនិតថ្មីនេះបង្កើតជាបទពិសោធថ្មី ។



បង្រៀនដោយ៖ យិន វណ្ណៈ



៣. ការអប់រំមានន័យថាការរីកចម្រើន

- បទពិសោធរបស់បុគ្គល គឺជាកត្តាចម្បងបំផុតនៅក្នុងដំណើរការនៃការរៀន ព្រោះវាបានបង្ហាញថាការអប់រំគឺជាដំណើរការដ៏ធំនៃការលូតលាស់តាមធម្មជាតិ។
- រាងកាយរបស់មនុស្សមានការរីកចម្រើនស្របទៅតាមទំនោររបស់ទារកគឺពេលដែលគេផ្តល់ឱ្យនូវប្រភេទអាហារត្រឹមត្រូវ និងមានលក្ខខណ្ឌណាមួយសមស្របសម្រាប់ប្រភេទលំហាត់ប្រាណ។
- គំនិតនឹងរីកចម្រើន ហើយអភិវឌ្ឍន៍ស្របតាមទំនោរផ្នែកខាងក្នុងនៅពេលមានកត្តាជំរុញត្រឹមត្រូវ និងមានលក្ខខណ្ឌល្អចំពោះការធ្វើលំហាត់ប្រាណត្រឹមត្រូវ។

បង្រៀនដោយ៖ យិន វណ្ណី

៣. ការអប់រំមានន័យថាការរីកចម្រើន

“ការអប់រំមិនត្រូវមានតម្លាធនោះឡើយ។
ការរៀនគួរតែធ្វាក់មកដល់សិស្សដូចនឹង
ការហែលទឹកនៃសត្វត្រូវទ្លុះទៅទឹកត្រី,
ការហោះហើរត្រូវទ្លុះទៅទឹបក្សី និង
ការរត់ត្រូវទ្លុះទៅទឹតតួរស៊ីៗឡើត”។
ខូមេនៀស (Comenius)





បង្រៀនដោយ៖ យិន វណ្ណៈ

៤. តើការបង្រៀនមានន័យដូចម្តេច ?



❖ **ជាការរៀបចំសកម្មភាពសិស្ស**

- របៀបបង្រៀនផ្តោតសំខាន់លើអ្វីដែលសិស្សធ្វើ, ការតភ្ជាប់ទំនាក់ទំនងជាផ្នែកនៃការឃ្លាំមើល។
- គ្រូធ្វើឱ្យសិស្សរវល់នឹងសកម្មភាពដោយដាក់ចេញវិធានជាក់លាក់, ច្បាស់លាស់ដើម្បីរៀន។
- ដំណើរការនៃការរៀនរួមមានទាំងគ្រូនិងសិស្ស ហើយការបញ្ចេញគំនិត ឬទស្សនៈគឺជាផ្នែកដ៏សំខាន់មួយនៃការចូលរួមរបស់សិស្ស។ ប៉ុន្តែ វាផ្តោតលើវិធីសាស្ត្របង្រៀនផងដែរ។

បង្រៀនដោយ៖ យិន វណ្ណី

៤. តើការបង្រៀនមានន័យដូចម្តេច ?

❖ ជាការអនុញ្ញាតឱ្យមានដំណើរការក្នុងការរៀន

- បង្កើតសហប្រតិបត្តិការដែលជាទំនាក់ទំនងរវាងសិស្សនិងគ្រូ។ គ្រូបង្កើតបរិយាកាសដែលមានការចូលរួម និងកែតម្រូវការយល់ច្រឡំរបស់សិស្ស។
- ផ្អែកលើតម្រូវការរបស់សិស្ស គ្រូនឹងប្រើវិធីសាស្ត្របង្រៀនផ្សេងៗជំនួសឱ្យរបៀបបង្រៀនតែមួយ។ សិស្សកាន់តែចង់ចូលរួមសកម្មនៅពេលស្មើពួកគេបង្កើតចំណេះដឹងដោយខ្លួនឯង ឬនៅក្នុងក្រុម។



បង្រៀនដោយ៖ យិន វណ្ណី

៤. តើការបង្រៀនមានន័យដូចម្តេច ?



❖ **ជាទិសដៅនៃការរីកចម្រើន ឬការលូតលាស់**

- ផ្តោតសំខាន់លើទិសដៅនៃការរីកចម្រើន, ការផ្តល់ប្រភេទត្រឹមត្រូវក្នុងការជំរុញនៅពេលអំណោយផលបំផុតសម្រាប់ការអនុវត្តដែលជំរុញការរីកចម្រើន ។
- ជំនួសឱ្យការធ្វើខ្លួនជាអ្នកទទួលខុសត្រូវ, ជាអ្នកធ្វើតាមទំនើងចិត្ត និងបង្ខំឱ្យអ្នកសិក្សាបំពេញតាមតម្រូវការរបស់ខ្លួន, ពេលនេះគ្រូក្លាយជាមគ្គទេសក៍, ប្រឹក្សាយោបល់ និងចាំឃ្លាំមើលសញ្ញារបស់អ្នកសិក្សាដើម្បីត្រៀមខ្លួនសម្រាប់ប្រភេទបទពិសោធថ្មីៗ ។

បង្រៀនដោយ៖ យិន វណ្ណី



៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីឥរិយាបថនិយម

- ឥរិយាបថទទួលតាមរយៈអន្តរកម្មជាមួយនឹងបរិស្ថាន។ ទ្រឹស្តីនេះចែងថាឥរិយាបថត្រូវបានរៀនពីបរិស្ថាន ហើយយល់ថាកត្តាធម្មជាតិមានឥទ្ធិពលតិចតួចលើឥរិយាបថ។
- ឥរិយាបថគឺកំណត់ដោយចេតនារបស់មនុស្ស និងដោយកម្លាំងបរិស្ថាន ហើយចេតនានោះជាប្រភេទសកម្មភាព និងបំណងប្រាថ្នារបស់មនុស្សតាមរយៈលទ្ធផលនៃទង្វើ។ ឥរិយាបថត្រូវបានកំណត់ដោយអ្នកដទៃជាជាងកំណត់ដោយឆន្ទៈសេរីរបស់បុគ្គលផ្ទាល់។

បង្រៀនដោយ៖ យិន វណ្ណី

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីបរិញ្ញាណនិយម

- ដំណើការនៃការគិត និងរបៀបនៃការគិតនៅក្នុងដំណើរការយល់ដឹងដែលជះឥទ្ធិពលដោយកត្តាខាងក្នុង និងខាងក្រៅ។
- ការរៀនកើតឡើង និងត្រូវបានជះឥទ្ធិពលដោយមនុស្ស បរិស្ថាន និងឥរិយាបថ។
- គំនិតខាងក្នុង និងកម្លាំងជុំវិញអាចដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃការយល់ដឹង។
- អន្តរកម្មសង្គមដែលឃើញនៅជុំវិញ ការអង្កេតឥរិយាបថ និងរបៀបដែលពួកគេបកស្រាយជះឥទ្ធិពលដល់ឥរិយាបថ និងការរៀន។



បង្រៀនដោយ៖ យិន វណ្ណៈ

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីស្ថានានិយម

- សិស្សធ្វើសកម្មភាពយ៉ាងសកម្ម ឬបង្កើតចំណេះដឹងផ្ទាល់ខ្លួន និងតថភាពត្រូវកំណត់ដោយបទពិសោធរបស់អ្នកសិក្សា ។ អ្នកសិក្សាប្រើចំណេះដឹងពីមុនជាមូលដ្ឋានគ្រឹះ និងពង្រឹងរបស់ថ្មីដែលពួកគេរៀន ។
- បទពិសោធបុគ្គលម្នាក់ៗធ្វើឱ្យការរៀនសូត្ររបស់ពួកគេមានលក្ខណៈប្លែកពីគេ ។
- គ្រូដែលយល់ពីទ្រឹស្តីស្ថាបនានិយមគិតថាសិស្សនាំបទពិសោធផ្ទាល់ខ្លួនដល់ថ្នាក់រៀនជារៀងរាល់ថ្ងៃ ។



បង្រៀនដោយ៖ យិន វណ្ណៈ

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន



❖ ទ្រឹស្តីនៃការរៀនតាមរយៈបទពិសោធ

- សិស្សជាអ្នកជួបប្រទះរឿងរ៉ាវផ្ទាល់ខ្លួនគេ និងរៀនពីបទពិសោធនោះ។
- បើគ្មានការឆ្លុះបញ្ចាំងទេ មនុស្សនឹងបន្តធ្វើខុសម្តងទៀត។
- **បទពិសោធប្រតិបត្តិ** គឺសំដៅលើការពិសោធឬជាការដាក់ខ្លួនឯងទៅក្នុងកិច្ចការ ហើយជាដំណាក់កាលដំបូងដែលមនុស្សអនុវត្តន៍ការងារដែលបានផ្តល់ឱ្យ។ ដំណាក់កាលនេះគឺជាដំណាក់កាលធ្វើ។

បង្រៀនដោយ៖ យិន វណ្ណៈ

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីមនុស្សនិយម

- មនុស្សនិយមរកឃើញក្នុងការគិតរបស់ អេរ៉ាស្មូស។ លោកជឿលើភាពល្អរបស់កុមារ, កុមារជាមនុស្សមានឆន្ទៈសេរី, មនសិការខាងសីលធម៌, មានសមត្ថភាពស្គាល់ហេតុផលវិចារណញ្ញាណ, យល់ដឹងខាងសោភ័ណភាព និងសភាវគតិសាសនា។
- គេគួរថែទាំយុវជនឱ្យបានល្អ និងមិនត្រូវបង្ខំឱ្យរៀនឬប្រញាប់ពេកទេ ពីព្រោះដំណើរការលូតលាស់របស់ពួកគេកើតទៀងជាដំណាក់ៗ។
- មនុស្សនិយមត្រូវបានអភិវឌ្ឍន៍ជាមួយទស្សនវិជ្ជាអប់រំរបស់ Rousseau និងPestalozzi។



បង្រៀនដោយ៖ យិន វណ្ណៈ

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីមនុស្សនិយម

- អ្នកសិក្សាគ្រប់គ្រងលើជោគវាសនារបស់ខ្លួន, ជាមនុស្ស ស្វយ័ត សេរីភាព ជម្រើស និងការទទួលខុសត្រូវ។
- អ្នកសិក្សាលើកទឹកចិត្តខ្លួនឯងដើម្បីសម្រេចបានផលនៃជីវិតកម្រិតខ្ពស់។ ការរៀនជាសកម្មភាពផ្ទាល់ខ្លួន។
- ការរៀនអាចកើតមានឡើងប្រសិនបើគ្រូដើរតួជាអ្នកសម្របសម្រួល។ គ្រូគួរបង្កើតបរិយាកាសដែលសិស្សមានអារម្មណ៍កក់ក្តៅ អាចពិភាក្សាអំពីគំនិតថ្មីៗ និងរៀនពីកំហុសរបស់ពួកគេ ដរាបណាពួកគេមិនត្រូវបានគំរាមកំហែងដោយកត្តាខាងក្រៅ។



បង្រៀនដោយ៖ យិន វណ្ណី

៥. ទ្រឹស្តីអំពីការរៀននិងការបង្រៀន

❖ ទ្រឹស្តីពិភពវេទយិត

- ការរៀនកើតឡើងគឺនៅពេលឥន្ទ្រិយទាំងប្រាំរបស់មនុស្ស (ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ) មានរំញោច។
- ជាការងាយស្រួល ប្រសិនបើគ្រូកំពុងបង្រៀនមេរៀនអនុវត្តន៍ជាក់ស្តែង ប៉ុន្តែ មិនមែនជាការងាយស្រួលទេ បើគ្រូកំពុងបង្រៀនមុខវិជ្ជាទ្រឹស្តី។
- ប្រសិនបើគ្រូអាចធ្វើឱ្យការសិក្សាមានភាពសប្បាយរីករាយ និងគួរឱ្យចាប់អារម្មណ៍ដែលទាក់ទងនឹងឥន្ទ្រិយទាំងនោះ វានឹងជួយឱ្យសិស្សរបស់អ្នកចងចាំប្រធានបទកាន់តែល្អ។

បង្រៀនដោយ៖ យិន វណ្ណៈ